**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.....១៤៧១.....អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់មេត្តាជ្រាបថាៈ ក្នុងអំឡុងពេល ៦ខែ ចុងឆ្នាំ ២០១២ នេះ មានលេចចេញនូវ Account Facebook មួយបានប្រើប្រាស់ឈ្មោះ «**អង្គភាពពន្ធដារ**» បង្ហោះផ្សាយចេញ (Post) ឯកសារការងារពន្ធដារ សេចក្តីព្រាងលិខិតបទដ្ឋានផ្សេងៗ របស់អគ្គនាយកដ្ឋានពន្ធដារ ហើយបានតាំងខ្លួនជាជំនួយការ ឬលេខាធិការ របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងពេល Chatting ជាមួយអ្នកដែលបាន Added Friend និងបានលួចបន្លំយកឈ្មោះមន្ត្រីពន្ធដារដែលជាថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ មកប្រើប្រាស់តាមវិធីផ្លាស់ (Random) ទៀតផង ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការបដិសេធទាំងស្រុងចំពោះការក្លែងបន្លំ និងលួចប្រើឈ្មោះមន្ត្រីពន្ធដារ ក្នុងការបង្ហោះផ្សាយចេញ (Post) នូវឯកសារការងារពន្ធដារ សេចក្តីព្រាងលិខិតបទដ្ឋានផ្សេងៗ ដែល Account Facebook ឈ្មោះ «**អង្គភាពពន្ធដារ**» មួយនេះបានប្រព្រឹត្តកន្លងមក ។ អគ្គនាយកដ្ឋានពន្ធដារ ពុំមានទស្សនវិស័យលើការបង្កើត Account Facebook សម្រាប់បង្ហោះផ្សាយចេញ (Post) នូវសេចក្តីជូនដំណឹង លិខិតបទដ្ឋានគតិយុត្តិសារពើពន្ធដែរ ព្រោះអគ្គនាយកដ្ឋានពន្ធដារ មានគេហទំព័រផ្ទាល់ (www.tax.gov.kh) សម្រាប់ដាក់បង្ហោះនូវសេចក្តីជូនដំណឹង លិខិតបទដ្ឋានគតិយុត្តិសារពើពន្ធ ផ្សព្វផ្សាយបម្រើសេវាជូនអ្នកជាប់ពន្ធ និងសាធារណជន ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់ថាគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ នឹងផ្តាច់ការទាក់ទង (Unfriend) ចេញពី Account Facebook ឈ្មោះ «**អង្គភាពពន្ធដារ**» ។/.

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708 / Fax: (855) 23 886 700